**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៥
ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦
សំណុំរឿងជំនុំជម្រះលេខ១៨១៣
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦
**សាលក្រមលេខ ៥៦៣ ក្រ២ "វ"**
ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០១៦ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៩៥ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទ ៖

១. ឈ្មោះ [redacted] ហៅ ស្មា ភេទប្រុស អាយុ ២៦ ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀន ថ្នាក់ទី៩ មុខរបរនៅផ្ទះ ទីកន្លែងកំណើត សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នផ្ទះជួល សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន ១ នាក់ ទោសពីមុន គ្មាន ។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦
ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

២. ឈ្មោះ [redacted] ភេទប្រុស អាយុ ៣២ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៥ មុខរបររត់ម៉ូតូឌុប ទីកន្លែងកំណើតភូមិពោធិ៍ ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត មានទីលំនៅបច្ចុប្បន្ន ផ្ទះជួល សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ទោសពីមុនគ្មាន ។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦
ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦



Scanned by CamScanner

៣.ឈ្មោះ [redacted] ហៅ គួក ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ សាសនា ព្រះពុទ្ធ កម្រិតវប្បធម៌រៀនថ្នាក់ទី៨ មុខរបរគ្មាន ទីកន្លែងកំណើតនៅ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ផ្ទះជួល សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស្លាប់- ម្តាយឈ្មោះ [redacted] រស់- នៅលីវ ទោសពីមុនគ្មាន។

លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឃាត់ខ្លួនថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦

ឃុំខ្លួនថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៦

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះឈ្មោះ [redacted] ភេទប្រុស អាយុ ៩៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ មន្ត្រីគយ មានទីលំនៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ២៨៥០ អ.យ.ព ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៦ របស់ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៧២៤ ដ.ដ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ជនរងគ្រោះឈ្មោះ [redacted] បានយកមេសោពណ៌ខ្មៅ ទៅចាក់ទ្វារជណ្តើរឡើងទៅលើផ្ទះជួល នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ រួចក៏ចូលទៅដេកលង់លក់ជាមួយក្រុមគ្រួសារ។ លុះដល់ម៉ោងប្រហែល ០៣ និង ៣០ នាទី រំលងអាធ្រាត ក៏មានជនជាប់ចោទចំនួនបីនាក់មានឈ្មោះ [redacted] ហៅ [redacted] ភេទ ប្រុស ឈ្មោះ [redacted] ហៅ ស្វា ភេទ ប្រុស និងឈ្មោះ [redacted] ភេទ ប្រុស បានជិះម៉ូតូ មួយគ្រឿង មកឈប់មុខផ្ទះជនរងគ្រោះ។ ដោយឃើញសភាពស្ងាត់ឈ្មោះ [redacted] និងឈ្មោះ [redacted] បានដើរចូលទៅដោយបានយកម្ជុលខ្វាស់ទៅឆ្កិះសោទ្វារឱ្យរបើក បន្ទាប់មកជនសង្ស័យទាំងពីរ នាក់បានដើរទៅជាន់ទីពីរ។ ពេលកំពុងតែដើរឡើងទៅ ស្រាប់តែមានអ្នកជិតខាងឃើញក៏ស្រែកថា ចោរៗ ភ្លាមនោះជនរងគ្រោះក៏បើកទ្វារផ្ទះចេញមកឃើញទ្វារជណ្តើរចំហរ ហើយមេសោរបូត ក៏ផ្អើលដល់ប្រជាពលរដ្ឋ រួចចាប់ខ្លួនជនជាប់ចោទទាំងបីនាក់បាន ហើយប្រគល់ឱ្យសមត្ថកិច្ចប៉ុស្តិ៍នគរបាលទឹកថ្លាតែម្តង។

## នាពេលសាកសួរ

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា : កាលពីយប់ថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦ វេលាម៉ោង១និង៣០នាទីរំលងអាធ្រាត្រ ខ្លួន និង ឈ្មោះ [redacted] នៅកន្លែងបាញ់ត្រីបានឲ្យឈ្មោះ [redacted] ឌុបម៉ូតូជូនខ្លួនទៅទារលុយបងប្អូននៅជិតទឹកថ្លា ពេលជិះដល់ក្រោយវត្តទឹកថ្លា ស្រាប់តែឃើញផ្ទះមួយ មានទុកកង់ ខ្លួនបានដើរចូលទៅ ជាមួយឈ្មោះ [redacted] ក៏បានម្ជុលខ្វាស់ឆ្កិះ សោរទ្វារដើរចូលទៅក្នុងផ្ទះបំណងយកកង់តែមិនបានយកក៏ត្រូវបានម្ចាស់គេទាន់ស្រែកថាចោរៗសមត្ថកិច្ច



Scanned by CamScanner

មកដល់ក៏ឃាត់ពួកខ្លួនតែម្តង ។ ចំណែកឈ្មោះ សរ សុជាតិ នៅឈរចាំម៉ូតូខាងក្រៅ ។

ជនជាប់ចោទឈ្មោះ [redacted]ានឆ្លើយថា ៖ ខ្លួនសុំបដិសេធ ដោយខ្លួនមិនបាន សមគំនិត ក្នុងការចូលលួចទេ យប់នោះឈ្មោះ [redacted]ិងឈ្មោះ[redacted]ហៅខ្លួនជាអ្នកជាក់ម៉ូតូឌុបឲ្យខ្លួន ឌុបទៅដោយឲ្យខ្លួនចំនួន១០០០០(មួយម៉ឺន)រៀល ដោយប្រាប់ខ្លួនថាទៅទារលុយប្អូន ដោយខ្លួនមិនបានឮពួកគេនិយាយថាទៅលួចទេ ពេលខ្លួនឌុបទៅដល់ខ្លួនបានឈប់ម៉ូតូពួកគេ ទាំង២នាក់បាន ចុះពីលើម៉ូតូដើរសំដៅផ្ទះមួយ ហើយខ្លួនបាននៅឈរចាំចម្ងាយ២០ម៉ែត្រពីពួកគេ ហើយខ្លួនឃើញឈ្មោះ [redacted]លូកដៃចូលក្នុងក្រង់ជាផ្តិះសោរឬអត់ខ្លួនអត់បានដឹងទេ ហើយខ្លួនឃើញឈ្មោះ[redacted] និងឈ្មោះ [redacted] ដើរចូលទៅ មួយសន្ទុះក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនបាន ហើយខ្លួនក៏មិន ទាន់បាន លុយពីពួកគេឡើយ។

ជនជាប់ចោទឈ្មោះ[redacted]ានឆ្លើយថា ៖ កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោង ប្រហែល ២រំលងអាធ្រាត្រ ខ្លួនបានទៅលេងហ្គេមបាញ់ត្រីនៅសង្កាត់ទឹកល្អក់៣ ជួបជាមួយ ឈ្មោះ[redacted]ហៅស្ពា ក៏បានបបួលខ្លួនទៅលួចគេនៅភូមិទឹកថ្លាហើយក៏បាននាំគ្នាជិះម៉ូតូឌុបរបស់ ឈ្មោះ [redacted]ាលដល់ភូមិក្រោយផ្សារទឹកថ្លាឈ្មោះ[redacted] ហៅស្ពា បានឲ្យម៉ូតូឈប់ហើយ ឈ្មោះ [redacted]និង ខ្លួន បានដើរចូលទៅផ្ទះមួយទ្វារបិទជិត ឃើញមានកង់មួយបំណង លួចយក ទៅលក់បានលុយចែកគ្នា ហើយឈ្មោះ [redacted]បានលូកដៃទៅក្នុងទ្វារផ្តិះសោរទ្វារបើក នាំគ្នាដើរ ចូលទៅ ក៏ត្រូវម្ចាស់ផ្ទះគេស្រែក ថា ចោរៗ ក៏ត្រូវ ចាប់ខ្លួនតែម្តង។ ចំណែកឈ្មោះ[redacted]ាំតែជា ម៉ូតូឌុបឈរ ចាំម៉ូតូមិនបាន ចូលទៅ ជាមួយទេ។

តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ[redacted]ានឆ្លើយនៅចំពោះមុខចៅក្រម ស៊ើបសួរថា កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ប្រហែលម៉ោង៤ទៀបភ្លឺពេលនោះ ខ្លួនឮសំលេង ស្រែកថាចោរៗ នៅល្វែងខាងលើផ្ទះដែលខ្លួនបានសង់ជាបន្ទប់ ជួលឲ្យគេខ្លួនក៏បានបើក ទ្វារខាង ក្រោយផ្ទះ ហើយឃើញសមត្ថកិច្ចកំពង់ប្រតិបត្តិការដោយកំពុង ភ្លង់ជនសង្ស័យម្នាក់ដែលនៅពួន ក្រោមជណ្តើរ ហើយសមត្ថកិច្ចក៏បានស្រែកឲ្យរាចេញមកហើយក៏ចាប់បានម្នាក់ ពេលនោះសមត្ថកិច្ច ក៏បានឡើងទៅជាន់ខាងលើចាប់បានម្នាក់ទៀត ពេលនោះខ្លួនក៏បានតាមមើលសមត្ថកិច្ចបណ្តើរ ជន សង្ស័យទាំងពីរមកខាងក្រៅ ហើយក៏បានឃើញម្នាក់ទៀតដែលសមត្ថកិច្ច ឃាត់បានសរុបគឺមានជន ល្មើស៣នាក់។ កន្លងមកអ្នកដែលនៅផ្ទះជួលជាន់លើ តែងតែបាត់បង់ទូរទស្សន៍ កុំព្យូទ័រ ម៉ូតូ គឺតែងតែគាស់សោរទ្វារបន្ទប់ចូលយកអីវ៉ាន់។ នៅថ្ងៃកើតហេតុនោះគឺជនសង្ស័យគាស់សោរទ្វារខាង មុខដើម្បីឡើងទៅជាន់ខាងលើ តែឡើងទៅជាន់ខាងលើមិនទាន់បានធ្វើអ្វីទេ សាក្សីបានឃើញហើយ ស្រែក រត់នាំគ្នាចុះមកក្រោមតែត្រូវសមត្ថកិច្ចខ្ទប់ហើយធ្វើការឃាត់ខ្លួនតែម្តង ខ្លួនបានមើលឃើញ សកម្មភាពនេះតាមកាមេរ៉ាសុវត្ថិភាព។ ខ្លួនសំណូមពរផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងមិនទាម ទារសំណងជម្ងឺចិត្តអ្វីទេ ។

តាមអំណានចម្លើយរបស់សាក្សីឈ្មោ[redacted]ានស្បថរួចហើយ បានឆ្លើយថា កាលពី ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងជិត៤ ទៀបភ្លឺ ពេលនោះពេលនោះខ្លួនទើប ចេញពីធ្វើការ ហើយត្រឡប់មកផ្ទះជួលក៏ឡើងទៅលើជាន់ទី៣ អង្គុយលេងជាមួយមិត្តភក្តិ នៅជាន់នោះ ព្រោះបន្ទប់



Scanned by CamScanner

ខ្លួននៅជាន់ទី២ភ្លេចយកសោរពុំមានអ្វីចូលក៏ត្រូវអង្គុយលេងចាំមិត្តភក្តិយកសោរមក ពេលនោះ ខ្លួនក៏បានឃើញមនុស្សប្រុសបីនាក់ ជិះម៉ូតូមកឈប់នៅមុខផ្ទះជួល ហើយហើយបានឃើញមនុស្ស ប្រុស២នាក់បានឡើងមកជាន់ទី២ ខ្លួនក៏សង្ស័យព្រោះថាអ្នកជួលផ្ទះនេះសុទ្ធតែជាអ្នកធ្វើការ និងសិស្ស តែ២នាក់នោះគឺមិនមែន ស្រាប់តែពេលនោះខ្លួនបានឃើញប៉ូលីសជិះល្បាតពីរម៉ូតូខ្លួនក៏ស្រែកថា ចោរៗ សមត្ថកិច្ចក៏បានឡើងមកជាន់លើធ្វើការឃាត់ខ្លួនបានទាំង២នាក់ ដែលឡើងមកជាន់ទី២នោះ និងម្នាក់ទៀតដែលនៅចាំនៅក្រៅ សរុបបានបីនាក់ ។ ខ្លួនបានឃើញពីរនាក់ដែលឡើងមកជាន់ទី២ នោះ ធីះសោរបន្ទប់គេ ដែលម្ចាស់បន្ទប់បានទៅស្រុកកំណើតចូលឆ្នាំអស់ ។ ពួកគេមិនទាន់ធ្លុះបានសម្រេចទេ ដោយពេលនោះខ្លួនឃើញប៉ូលីសល្បាតមកឈប់ សួរម្នាក់ទៀតដែលនៅចាំខាង ក្រៅភ្លាមខ្លួនក៏ស្រែកភ្លាមតែម្តង ។

តាមអំណានកំណត់ហេតុទទួលវត្ថុចាប់យកលេខ៨២៨ វ.អ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ មាន៖ ១. មេសោរចិនចំនួន១

២. ទួរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

៣. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី) ។

តាមអំណានរបាយការណ៍សំយោគលេខ០៨៣/១៦ របក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខថា៖ ជនសង្ស័យចំនួន៣នាក់ ដែលឃាត់ខ្លួនបាន មាន ឈ្មោះ[redacted] ឈ្មោះ[redacted] ឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងលួច កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ៣ និង៣០នាទី រំលងអាធ្រាត្រ នៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោលជនជាប់ចោទទាំង៣ ឃើញថាជនជាប់ចោទ ឈ្មោ[redacted] បានឆ្លើយសារភាពថាខ្លួនពិតជាបានប៉ុនប៉ងធ្វើ សកម្មភាពលួច ប្រព្រឹត្តនៅនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែន សុខ រាជធានីភ្នំពេញ ប្រាកដមែន ។ហើយឈ្មោះ ចាន់ [redacted]ិងឈ្មោ[redacted]ពិភាក្សាគ្នាដើររកលុយ ចំណែកឈ្មោះ[redacted]អ្នករត់ម៉ូតូឌុប នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែខ្លួនបានឌុប ឈ្មោះ [redacted]ងឈ្មោ[redacted] ដែលចម្លើយនេះស្របជាមួយភស្តុតាង ដែលឈ្មោះ ចាន់ [redacted]ិងឈ្មោះ [redacted]ចូលធ្វើសកម្មភាព ឈ្មោះ [redacted]បានឈប់ម៉ូតូចម្ងាយ២០ម៉ែត្រ រីឯ ឈ្មោ[redacted]ក៏បានឆ្លើយសារភាពដូចឈ្មោ[redacted] ដែរ ចម្លើយទាំងបី គឺមានភាពស៊ីចង្វាក់គ្នាជាមួយ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយសាក្សី តែការធ្វើសកម្មភាពរបស់ជនទាំងបី គឺមិនបានសម្រេច ដូច្នេះតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរ លេខ ២៨៥០ អ.យ.ព ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១៦ ទុកដដែល សុំឱ្យតុលាការ សម្រេច ទៅតាមច្បាប់ ។



Scanned by CamScanner

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា** ក្នុងពេលសវនាការកូនក្តីខ្លួនឈ្មោះ [redacted]ឹងឈ្មោះ [redacted] បានឆ្លើយសារភាពជូន តុលាការដោយបាន ដឹងពីកំហុសរបស់ខ្លួនហើយ ដូចនេះខ្លួនសុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted]នឆ្លើយថាខ្លួនមិនបានចូលរួមប្រព្រឹត្តទេ ហើយចម្លើយនេះដូចចម្លើយនៅ សមត្ថកិច្ច និងចម្លើយនៅចៅក្រមស៊ើបសួរ ថាខ្លួនគ្រាន់តែឧបជូនឈ្មោះ[redacted] និងឈ្មោះ[redacted] ទៅយកលុយប្អូនដោយទទួលតម្លៃចំនួន១០០០០(មួយម៉ឺន)រៀល ហើយអ្នកទាំងពីរបាន ឲ្យខ្លួនឈប់នៅរងចាំ ដោយមិនបានដឹងថាអ្នកទាំងពីរចូលធ្វើសកម្មភាព ផ្តិះសោរទ្វារបំណាងចូលលួច សម្ភារៈរបស់គេទេ។ ដូច្នេះហើយខ្លួនសុំឲ្យតុលាការសម្រេចឲ្យឈ្មោះ[redacted]បានរួចផុតពី បទចោទប្រកាន់ ។

## ជនជាប់ចោទឆ្លើយសម្តីចុងក្រោយ

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ៖ សុំឲ្យតុលាការមេត្តាជួយ សម្រាលទោស ដល់ខ្លួនផង ខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ[redacted]បាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការសម្រាលទោសខ្លួនដឹងកំហុសហើយ ។

ជនជាប់ចោទឈ្មោះ[redacted]ាននិយាយសម្តីចុងក្រោយថា ៖ សុំឲ្យតុលាការលើកលែងចោទ ប្រកាន់ ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ
ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យភស្តុតាង
ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សំអាងហេតុ</u>

១. កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល៣ និង៣០ នាទី រំលងអាធ្រាត្រ ជនជាប់ចោទឈ្មោះ [redacted] ហៅ ស្នា, ឈ្មោះ[redacted]ហៅ តូក និងឈ្មោះ [redacted]ាតជាបានផ្តើមធ្វើសកម្មភាពប៉ុនប៉ងលួចទ្រព្យសម្បត្តិ នៅផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប៉ុន្តែមានអ្នកជិតខាងឃើញក៏ស្រែកថាចោរៗភ្លាមនោះជនរងគ្រោះក៏ភ្ញាក់ពី ដំណេកក៏បើកទ្វារចេញមកមើលឃើញ ទ្វារជណ្តើរចំហរក៏ ផ្អើលដល់ប្រជាពលរដ្ឋ នោឡោឡ ដល់ សមត្ថកិច្ចកំពុងដើរល្បាតមកដល់កន្លែងកើតហេតុក៏បានអន្តរាគមន៍ឡើងលើផ្ទះចាប់បានជនជាប់ចោទចំនួន២នាក់ឈ្មោះ[redacted]និងឈ្មោះ[redacted]ចំណែកឈ្មោះ [redacted] ចាប់ខ្លួនបាននៅខាង



Scanned by CamScanner

ក្រោមកំពុងមើលម៉ូតូរងចាំអ្នកទាំងពីរចេញបង្កសំណុំរឿងបញ្ជូនមកតុលាការតែម្តង ប្រាកដមែន ។

២. ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចប្រាកដមែន ដែលចម្លើយសារភាពនេះ ស្របទៅនឹងចម្លើយរបស់ជនរងគ្រោះ និងសាក្សី បានឆ្លើយនៅគ្រប់ដំណាក់កាលនីតិវិធី ស្របទៅនឹងរបាយការណ៍ សំយោគរបស់មន្ត្រី នគរបាលយុត្តិធម៌ ហើយក៏ស្របទៅនឹងភស្តុតាង ជាឯកសារផ្សេងៗទៀតដែល មាននៅក្នុងសំណុំរឿង ផងដែរ ។

៣. ថ្វីត្បិតតែនាពេលសវនាការជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបដិសេធថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេប៉ុន្តែចម្លើយនេះគ្រាន់តែជាការដោះសារប៉ុណ្ណោះព្រោះថាតាម ចម្លើយរបស់ជនរងគ្រោះ និងចម្លើយរបស់សាក្សីបានបញ្ជាក់ថាជនជាប់ចោទពិតជាបានប៉ុនប៉ងធ្វើសកម្មភាពលួចទ្រព្យរបស់អ្នកដទៃ នៅយប់ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ដែលស្របទៅ នឹងរបាយការណ៍សំយោគ ប្រាកដមែន។

៤. ជនជាប់ចោទឈ្មោះ [redacted], ឈ្មោះ [redacted] និងឈ្មោះ [redacted] ជានីតិជនដែលពុំមានភស្តុតាង ណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានការយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ។

៥. សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទ បានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការចាប់ផ្តើមប្រព្រឹត្តសកម្មភាពយកទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ប៉ុន្តែត្រូវអាក់ខានមិនបានសម្រេចដោយ សារតែកម្លាំងនគរបាលមកពារាំងប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសណ្តាប់សាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជនដែលច្បាប់ការពារ ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅ ចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមាន ចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៨.ជនជាប់ចោទជាជនក្រីក្រ និងមានកម្រិតវប្បធម៌ទាប ។

៩.វត្ថុចាប់យកតម្កល់រឹបអូសមាន៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី)

១០. ជនជាប់ឈ្មោះ [redacted] ត្រូវបានឃុំខ្លួនថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១៦ ។

១១. ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានឃុំខ្លួនថ្ងៃ១៣ ខែមេសា ឆ្នាំ ២០១៦ ។

១២. ជនជាប់ចោទឈ្មោះ [redacted] ត្រូវបានឃុំខ្លួនថ្ងៃទ១៣ ខែមេសា ឆ្នាំ ២០១៦ ។



Scanned by CamScanner

# **ហេតុដូច្នេះសម្រេច**

១. ផ្ដន្ទាទោស ៖

**ក.** ឈ្មោះ [redacted] ហៅស្វា ភេទប្រុស អាយុ ២៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

**ខ.** ឈ្មោះ [redacted] ហៅតួក ភេទប្រុស អាយុ ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ៤ (បួន)ឆ្នាំ

**គ.** ឈ្មោ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំសញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់៤ (បួន)ឆ្នាំ

ពីបទ **ប៉ុនប៉ងលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣៦ ផ្លូវលំ ភូមិផ្សារទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ ២០១៦។

តាមមាត្រា ២៧ មាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២. វត្ថុចាប់យកត្រូវរឹបអូសតាមមាត្រា៦២, មាត្រា៦៣ នៃក្រមព្រហ្មទណ្ឌគឺ៖

ក. មេសោរចិនចំនួន១

ខ. ទូរស័ព្ទដៃចំនួន១ (ពណ៌ខ្មៅបែកអេក្រង់ចាស់)

គ. ម៉ូតូចំនួន១គ្រឿង ម៉ាកសង់សេ១០០ ពណ៌ខ្មៅសេរី៩៧ ពាក់ស្លាកលេខ ខ៣៣៥២ ក.ណ ១ (មិនប្រក្រតី)។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទនិងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៦
**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner